**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ**...៥១...សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ

---

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃការងាររបស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** បង្កើតក្រុមការងារដឹកនាំដំណើរការសុខដុមនីយកម្មការងារផែនការ ចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ ចំណុះគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហៅកាត់ថា «**ក.ស.ផ.ច.ហ**» ។

www.pheakdeylaw.com

**ប្រការ ២ :** **គសឥទហ** រួមមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១- រដ្ឋលេខាធិការក្រសួងផែនការ | ប្រធាន |
| ២- អគ្គលេខាធិការ ឬអគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- អគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤- អគ្គនាយកផែនការនៃក្រសួងផែនការ | អនុប្រធានប្រចាំការ |
| ៥- អគ្គនាយករងផែនការនៃក្រសួងផែនការ | សមាជិក និងជាលេខាធិការ |
| ៦- តំណាងក្រសួងផែនការ | សមាជិក |
| ៧- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៩- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |

**ប្រការ ៣:** **គសឥទហ** មានភារកិច្ចដូចខាងក្រោម :

- ដឹកនាំដំណើរការសិក្សា និងវាយតម្លៃឡើងវិញ នូវតួនាទីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ព្រមទាំងយន្តការ និងអភិក្រម ពាក់ព័ន្ធនឹងការរៀបចំផែនការ ការគ្រប់គ្រង សម្របសម្រួល និងការអនុវត្តចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ ។
- ដឹកនាំដំណើរការសិក្សា និងលើកសំណើវិធានការធ្វើសុខដុមនីយកម្មចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីអោយមានការឯកភាពតែមួយ មានលំដាប់លំដោយតាមប្រតិទិន ប្រកបដោយភាពស៊ីសង្វាក់ ដែលអាចបង្កើតបានជាផែនការចំណាយថវិកាដ៏ល្អ និងគ្រប់ជ្រុងជ្រោយ ព្រមទាំងមានសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ ដូចបានកំណត់ក្នុងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។
- តាមដានការអនុវត្តផែនការសកម្មភាពទាំងឡាយ ដែលត្រូវបានដាក់ចេញសម្រាប់កិច្ចដំណើរការសុខដុមនីយកម្មចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងហិរញ្ញប្បទានសហប្រតិបត្តិការ ហើយស្នើយោបល់តម្រែតម្រង់ទិស និងដោះស្រាយបញ្ហា ។

**ប្រការ ៤ :** **គសឥទហ** ត្រូវរាយការណ៍ជាប្រចាំ អំពីលទ្ធផលនៃការងាររបស់ខ្លួន ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់ការណែនាំ និងសម្រេច។ ក្នុងករណីត្រូវចាត់វិធានការលើសពីសមត្ថកិច្ចរបស់ខ្លួន គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរាយការណ៍សុំការណែនាំ និងការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៥ :** **គសឥទហ** អាចសហការ ឬស្នើអោយមានកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងករណីចាំបាច់ ។

www.pheakdeylaw.com

**ប្រការ ៦ :** **គសផខហ** មានលេខាធិការដ្ឋាននៅក្រសួងផែនការ សម្រាប់ជាជំនួយការក្នុងការបំពេញការងាររបស់ខ្លួន។ តួនាទីរបស់លេខាធិការដ្ឋាន និងសមាសភាពនៃមន្ត្រីលេខាធិការដ្ឋាន នឹងត្រូវបង្កើតឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ តាមសំណើរបស់ **គសផខហ** ។

**ប្រការ ៧ :** សមាជិកទាំងអស់នៃក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ ក្នុងករណីប្រធានអវត្តមាន តាមការអញ្ជើញរបស់អនុប្រធាន (តាមការប្រគល់សិទ្ធិរបស់ប្រធាន) ។

**ប្រការ ៨ :** **គសផខហ** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ ។

**ប្រការ ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល
- លេខាធិការដ្ឋានគណៈកម្មាធិការ គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចប្រការ ៩
- ឯកសារ-កាលប្បវត្តិ